អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ ២០១៨

# សេចក្តីប្រកាសព័ត៌មាន

## អង្គបុរេជំនុំជម្រះចេញសេចក្តីពិចារណារបស់ខ្លួនលើបណ្តឹងឧទ្ធរណ៍ របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលសម្រេចលើកលែងចោទប្រឆាំងនឹងអ៊ឹម ចែម

អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញសេចក្តីពិចារណារបស់ខ្លួន លើពាក្យបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានសម្រេចលើកលែងការចោទប្រកាន់ប្រឆាំងនឹងអ៊ឹម ចែម លើបទល្មើសព្រហ្មទណ្ឌនានា ដោយមូលហេតុមិនមានយុត្តាធិការបុគ្គល។

ជាឯកច្ឆ័ន្ទ អង្គបុរេជំនុំជម្រះ យល់ឃើញថា មានការខ្វះចន្លោះនៃនីតិវិធី ជាពិសេសទាក់ទងនឹងការកំណត់ភស្តុតាង និងការពន្យារពេល ដោយមិនសមស្របក្នុងការបិទការស៊ើបអង្កេត។ អង្គបុរេជំនុំជម្រះបានសម្រេចថា ច្បាប់ជាធរមានចំពោះមុខ អ.វ.ត.ក មិនបានដកហូតនូវសមត្ថកិច្ចរបស់តុលាការជាតិនោះទេ។

ចៅក្រមទាំង ៥រូបរបស់អង្គបុរេជំនុំជម្រះ មានការយល់ឃើញផ្សេងគ្នាចំពោះអង្គសេចក្តីនៃបណ្តឹងឧទ្ធរណ៍នេះ។ ចៅក្រម ៣ រូប បានយល់ឃើញថា អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលចំពោះអ៊ឹម ចែម។ ចៅក្រម ២ រូប បានយល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់ក្នុងការចោទប្រកាន់ អ៊ឹម ចែម ថាជាជនម្នាក់ក្នុងចំណោមមនុស្សផ្សេងទៀត ដែលជាអ្នកទទួលខុសត្រូវខ្ពស់បំផុត និងជឿជាក់ថា អ.វ.ត.ក មានយុត្តាធិការបុគ្គលលើគាត់។

ដើម្បីបដិសេធសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេត យើងត្រូវការសំឡេងគាំទ្រ ៤ លើ៥ ដូច្នេះសេចក្តីសម្រេចអំពីកង្វះយុត្តាធិការបុគ្គលលើ អ៊ឹម ចែម ត្រូវបានតម្កល់។ សេចក្តីសម្រេចនេះនឹងបិទបញ្ចប់នូវសំណុំរឿង អ.វ.ត.ក ០០៤/១។

សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ក៏ដូចជាសេចក្តីសម្រេចដែលត្រូវបានប្តឹង ត្រូវបានផ្សព្វផ្សាយក្នុងគេហទំព័ររបស់ អ.វ.ត.ក https://www.eccc.gov.kh/km/node/40347 ឬ www.eccc.gov.kh

*សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖*


លោក **នេត្រ ភក្ត្រា**

ប្រធានផ្នែកកិច្ចការសាធារណៈ និងជាមន្ត្រីនាំពាក្យ អ.វ.ត.ក

ទូរសព្ទចល័ត៖ ៨៥៥ (0) ១២ ៤៨៨ ១៥៦ ឬ (0) ១២ ៤៨៣ ២៨៣

ទូរសព្ទលើតុ៖ ៨៥៥ (0)២៣ ៨៦១ ៦៥៤

អ៊ីមែល៖ neth.pheaktra@eccc.gov.kh